## សំរេច

ប្រការ ១ : លុបកិច្ចព្រមព្រៀងវិនិយោគព្រៃសម្បទានរបស់ក្រុមហ៊ុន ចំនួន ០៣ ដែលពុំបានគោរពតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង ដូចមានឈ្មោះខាងក្រោម ៖

១-ក្រុមហ៊ុន Lansong International Co.,Ltd ដែលមានព្រៃសម្បទានស្ថិតនៅខេត្តព្រះវិហារ មានផ្ទៃដីសរុប ចំនួន ១៣២.០០០ ហិកតា ។

២-ក្រុមហ៊ុន Long Day Machinery Industry Co.,Ltd ដែលមានព្រៃសម្បទាន ស្ថិតនៅខេត្តកំពង់ស្ពឺ និងកំពត មានផ្ទៃដីសរុប ចំនួន ៩៨.០០០ ហិកតា ។

៣-ក្រុមហ៊ុន Cambodia Timber Product PTY Ltd ដែលមានព្រៃសម្បទាន ស្ថិតនៅខេត្តកំពត មានផ្ទៃដីសរុប ចំនួន ៣៤.៩២៥ ហិកតា ។

ប្រការ ២ : ការលុបកិច្ចព្រមព្រៀងព្រៃសម្បទានរបស់ក្រុមហ៊ុនទាំង០៣ ដែលមានចែងក្នុងប្រការ១ ខាងលើ រាជរដ្ឋាភិបាលមិនទូទាត់សងសំណងឡើយ ។

ប្រការ ៣ : ព្រៃសម្បទានដែលដកហូតពីក្រុមហ៊ុនទាំង ០៣ខាងលើនេះ ត្រូវរក្សាជាតំបន់ព្រៃបំរុងទុក ។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងក្រុមហ៊ុនទាំង០៣ ដែលមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ២៨ សសរ

### ស្តីពី

### ការបង្កើតក្រុមការងារ អន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៧/០១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

-បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ/បក ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន

-តាមសំណើរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សំរេច

ប្រការ ១ : បង្កើតក្រុមការងារសំរាប់ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿង ញៀនដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| -អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ជាប្រធាន |
| -រដ្ឋលេខាធិការ ក្រសួងសុខាភិបាល ០១រូប | ជា អនុប្រធាន |
| -អគ្គលេខាធិការរង នៃ អ.ជ.ប.គ.ញ ០១រូប | ជា អនុប្រធាន |
| -អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម ០១រូប | ជា សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម ០១រូប | ជា សមាជិក |
| -អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ០១រូប | ជា សមាជិក |
| -អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១រូប | ជា សមាជិក |
| -នាយករងទីចាត់ការគយ និងរដ្ឋាករ ០១រូប | ជា សមាជិក |
| -ប្រធាននាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. | ជា សមាជិក |
| -ប្រធានមន្ទីរប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ | ជា សមាជិក |

ប្រការ ២ : ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចតទៅ :

-ផ្លាស់ប្តូរ និងផ្តល់ព័ត៌មានជាប្រចាំរវាងក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសព័ត៌មានដែលទាក់ទងដល់ការនាំចូល និងចែកចាយសារធាតុផ្សំ ដើម្បីក្តាប់បានអំពីបរិមាណ និង គុណភាព ការស្តុកទុក ព្រមទាំងតំរូវ ការតាមបណ្តារោងចក្រ សហគ្រាស មូលដ្ឋានផលិតកម្ម ពាណិជ្ជកម្មដែលប្រើប្រាស់សារធាតុផ្សំ (Precursors) ។

-លើកឡើងនូវវិធានការចាំបាច់ ដើម្បីធានាគ្រប់គ្រងការធ្វើចរាចរចែកចាយសារធាតុញៀន សារធាតុគីមីផ្សំគ្រឿងញៀន សំដៅទប់ស្កាត់បាននូវរាល់បាតុភាពបង្វែរសារធាតុផ្សំពីជំនួញត្រឹមត្រូវតាមច្បាប់ ទៅផលិតគ្រឿងញៀនស្រវឹងខុសច្បាប់ ។

-ត្រួតពិនិត្យគ្រប់ប្រភេទថ្នាំ ចំរាញ់ចេញពីរុក្ខជាតិញៀន និងសារធាតុគីមីផ្សំបញ្ចូលគ្នា ទៅជាឱសថបុរាណ សម័យនិងថ្នាំបុរាណចិន ។ល។ ដែលស្តុកទុក ឬធ្វើការចរាចរលក់តាមទីផ្សារសាធារណៈ ។

-ស្រាវជ្រាវត្រួតពិនិត្យរាល់ឯកសារទាក់ទងនឹងការសុំអាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំ របស់បណ្តាស្ថាប័នរោងចក្រ សហគ្រាស ដែលទទួលការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច ។

-តាមដានត្រួតពិនិត្យរាល់ផែនការផលិតរបស់ក្រុមហ៊ុនឱសថ ឧស្សាហកម្មគីមី លើបទដ្ឋានបច្ចេកទេស ការស្តុក ការចែកចាយវត្ថុធាតុដើម មានលក្ខណៈជាសារធាតុគីមីផ្សំប៉ះពាល់សរសៃប្រសាទ ។

-ផ្តល់យោបល់ទៅក្រសួងពាក់ព័ន្ធ ដើម្បីចាត់វិធានការធានាបង្ការលើការបង្វែរសារធាតុផ្សំ ។

ប្រការ ៣ : សមាជិកក្រុមការងារនីមួយៗ មានភារកិច្ចប្រមូលគ្រប់ព័ត៌មានដែលទាក់ទងនឹងសារធាតុផ្សំ ព្រមទាំងវាយតម្លៃលើទិន្នន័យ និងភាពមិនប្រក្រតីនៃការនាំចេញនាំចូលសារធាតុផ្សំ ដែលពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន ឬ អង្គភាពរបស់ខ្លួន ហើយរាយការណ៍ជាប្រចាំតាមរបៀបរបបការងារដែលប្រធានបានកំណត់ ។

ប្រការ ៤ : សមាជិកក្រុមការងារត្រួតពិនិត្យសារធាតុផ្សំគ្រឿងញៀន ត្រូវចូលរួមប្រជុំអោយបានទៀងទាត់ តាមការកោះអញ្ជើញរបស់ប្រធាន ។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធានតាមការប្រគល់សិទ្ធិពីប្រធាន ។

ប្រការ ៥ : ក្រុមការងារត្រួតពិនិត្យសារធាតុផ្សំគ្រឿងញៀន ជាក្រុមជំនាញបច្ចេកទេស ធ្វើជាសេនាធិការអោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្តល់មតិជូនរាជរដ្ឋាភិបាល សំរាប់កម្មវិធីត្រួតពិនិត្យសារធាតុផ្សំគ្រឿងញៀននៅកម្ពុជា ហើយក្រុមការងារនេះនឹងអនុវត្តជាក់ស្តែងទៅតាមការដឹកនាំរបស់ប្រធាន ។

ប្រការ ៦ : ក្រុមការងារត្រួតពិនិត្យសារធាតុផ្សំគ្រឿងញៀន មានទីតាំងនៅក្នុងអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ប្រការ ៧ : ក្រុមការងារត្រួតពិនិត្យសារធាតុផ្សំគ្រឿងញៀន មានសិទ្ធិបង្កើតលេខា០១ក្រុម ដោយចាត់តាំងមន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយការងារតាមការចាំបាច់ ។

ប្រការ ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការក្រុមប្រឹក្សា

អភិវឌ្ឍន៍កម្ពុជា និង គ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០០

## សេចក្ដីសំរេច លេខ ២៩ សសរ

## ស្ដីពី

## ការបង្កើត គណៈកម្មការចំរុះ កម្ពុជា-ប្រូណេ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះ កម្ពុជា-ប្រូណេ ដែលមានសមាសភាពដូចខាងក្រោម :

-ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ប្រធាន

-ឯកឧត្ដម **អ៊ុច គឹមអន** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

-ឯកឧត្ដម **ខុង សំនួន** អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

-ឯកឧត្ដម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

-តំណាង ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

-តំណាង ទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

-តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

-តំណាង ក្រសួងពត៌មាន សមាជិក

-តំណាង ក្រសួងសុខាភិបាល សមាជិក